ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃចន្ទ ៤ រោច ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦*
*រាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២២*

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជំនួបសម្តែងការគួរសមដើម្បីជម្រាបលាឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី នាឱកាសដែលឯកឧត្តម Pablo Kang ឯកអគ្គរាជទូតអូស្ត្រាលី បញ្ចប់អាណត្តិបេសកកម្មការទូតនៅប្រទេសកម្ពុជា និង ពិធីចុះហត្ថលេខាលើកិច្ចសម្រួលបំពេញបន្ថែម សម្រាប់កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់
“Cambodia-Australia Partnership for Resilient Economic Development (CAP RED) Program”

នារសៀលថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២២, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបសម្តែងការគួរសមជាមួយឯកឧត្តម **Pablo Kang** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលនឹងត្រូវបញ្ចប់អាណត្តិបេសកកម្មការទូត នាពេលឆាប់ៗខាងមុខ និង ដើម្បីចុះហត្ថលេខាលើកិច្ចសម្របសម្រួលបំពេញបន្ថែម សម្រាប់កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (Cambodia-Australia Partnership for Resilient Economic Development, CAP RED) Program ។

ក្នុងជំនួបសម្តែងការគួរសមដើម្បីជម្រាបលាខាងលើ **ឯកឧត្តមឯកអគ្គរាជទូតអូស្ត្រាលី** បានសម្តែងនូវសេចក្តីរីករាយ និងអបអរសាទរ ចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលទទួលបានជោគជ័យ ក្នុងការរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤០ និងទី ៤១ ព្រមទាំងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា នៅថ្ងៃទី ១៣-១៧ ខែវិច្ឆិកា ឆ្នាំ ២០២២ កន្លងទៅនេះ ។ ឯកឧត្តមឯកអគ្គរាជទូតបានសម្តែងនូវមោទនភាពចំពោះសមិទ្ធផល ដែលសម្រេចបានជាផ្លែផ្ការបស់រដ្ឋាភិបាលទាំងពីរ ក្នុងអាណត្តិបេសកកម្មការទូតរបស់ឯកឧត្តម ចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២២ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការទ្វេភាគី ពិសេសការសម្រេចបាននូវការផ្តល់ហិរញ្ញប្បទានឥតសំណង សម្រាប់ជួយកម្ពុជាក្នុងវិស័យសំខាន់ៗមួយចំនួន ដូចជា វិស័យកសិកម្ម និងការកែច្នៃផលិតផលកសិកម្ម, ការគាំពារសង្គម, សកម្មភាពកំចាត់មីននៅកម្ពុជា, ការចូលរួមប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩, ថាមពលស្អាត និងការវិនិយោគបៃតង, និងការជួយរៀបចំសេចក្តីព្រាងឯកសារគោលនយោបាយមួយចំនួនទៀត ។ល។

**ឯកឧត្តមឯកអគ្គរាជទូតអូស្ត្រាលី** បានជម្រាបថា កម្មវិធី CAP RED ត្រូវបានហិរញ្ញប្បទានតាមរយៈមូលនិធិពីក្រសួងការបរទេស និងពាណិជ្ជកម្ម នៃរដ្ឋាភិបាលអូស្ត្រាលី តាមរយៈស្ថានទូតអូស្ត្រាលីប្រចាំនៅកម្ពុជា នូវហិរញ្ញប្បទានឥតសំណងចំនួនប្រមាណ ៨៧ លាន ដុល្លារអូស្ត្រាលី (ប្រមាណ ៦៥ លាន ដុល្លារអាមេរិក) សម្រាប់រយៈពេល ៥ ឆ្នាំ

គិតចាប់ពីខែមិថុនា ឆ្នាំ ២០២២ ដល់ខែមិថុនា ឆ្នាំ ២០២៧ ។ កម្មវិធី CAP RED នឹងមានការសហការអនុវត្តរួមគ្នារវាងវិស័យឯកជន និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកំណត់ និងរិះរកដំណោះស្រាយ ដើម្បីសម្រេចបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាព, ភាពធន់ និងបរិយាប័ន្ន ដោយផ្តោតលើវិស័យគោលចំនួន ៤ គឺ ១.ហេដ្ឋារចនាសម្ព័ន្ធ; ២.ពាណិជ្ជកម្ម និងវិនិយោគ; ៣.កសិកម្ម និងកសិឧស្សាហកម្ម; និង ៤.យេនឌ័រ និងបរិយាប័ន្ន ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះបេសកកម្មការទូតប្រកបដោយជោគជ័យរបស់ឯកឧត្តមឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា ចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២២ ។ ទន្ទឹមនេះ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានថ្លែងអំណរគុណផងដែរ ចំពោះរដ្ឋាភិបាលអូស្ត្រាលីដែលតែងតែបានជួយគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍលើវិស័យសេដ្ឋកិច្ច, សង្គម និងសុខមាលភាពប្រជាជន ព្រមទាំងបានចូលរួមគាំទ្រកម្ពុជា ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ តាមរយៈការផ្តល់នូវជំនួយជាវ៉ាក់សាំង និងការចូលរួមការស្តារសេដ្ឋកិច្ចកម្ពុជាឡើងវិញក្នុងពេលអន្តរកាលនេះ ។

ជាថ្មីម្តងទៀត, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវក្តីរីករាយ និងមោទនភាពចំពោះចំណងការទូតរវាងរាជរដ្ឋាភិបាលនៃប្រទេសទាំងពីរ ជាពិសេស តាមរយៈកិច្ចខិតខំរបស់ឯកឧត្តមឯកអគ្គរាជទូត **Pablo Kang** រហូតឈានដល់ការចុះហត្ថលេខាលើកិច្ចសម្របសម្រួលបំពេញបន្ថែម សម្រាប់កម្មវិធីភាពជាដៃគូ កម្ពុជា-អូស្ត្រាលី សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយភាពធន់ (Subsidiary Arrangement for CAP RED Program) នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ២០២២ នេះ ។ កិច្ចសម្របសម្រួលបំពេញបន្ថែមនេះ គឺជាឯកសារគោលសម្រាប់រៀបចំយន្តការជាក់ស្តែង ដើម្បីឈានដល់ការអនុវត្តប្រកបដោយជោគជ័យ នូវកម្មវិធី CAP RED ដែលជាក្របខណ្ឌរួមនៃការផ្តល់ហិរញ្ញប្បទានឥតសំណងរបស់ក្រសួងការបរទេស និងពាណិជ្ជកម្ម ចំពោះប្រជាជនកម្ពុជា ។

ជាកិច្ចបញ្ចប់, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការវាយតម្លៃខ្ពស់សារជាថ្មីចំពោះការបញ្ចប់បេសកកម្មការទូតប្រកបដោយជោគជ័យរបស់ឯកឧត្តម **Pablo Kang** ឯកអគ្គរាជទូតអូស្ត្រាលីប្រចាំនៅកម្ពុជា និងបានជូនពរឯកឧត្តមឯកអគ្គរាជទូត ទទួលបាននូវភាពជោគជ័យក្នុងបេសកកម្មថ្មីខាងមុខ និងបានសម្តែងនូវភាពសុទិដ្ឋិនិយមថា កិច្ចសហប្រតិបត្តិការ អូស្ត្រាលី-កម្ពុជា នឹងកាន់តែរឹងមាំ និងផ្តល់លទ្ធផលជាផ្លែផ្កា, ទាំងក្នុងក្របខណ្ឌទ្វេភាគី, ក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ ៕